ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 20

# គណនេយ្យសម្រាប់អំណោយរដ្ឋាភិបាល និងការលាតត្រដាងព័ត៌មានជំនួយរដ្ឋាភិបាល

## Accounting for Government Grants and Disclosure of Government Assistance

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** " ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខុមាលភាពរបស់ប្រជាជនឲ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឲ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង *“ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”* ត្រូវបានដាក់ឲ្យប្រើដោយប្រកាស *លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ព័ន្ធ ឲ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ងី តាយី**

## វិសាលភាព

**១ ស្តង់ដានេះត្រូវយកមកប្រើប្រាស់ក្នុងគណនេយ្យ និងការលាតត្រដាងអំណោយរដ្ឋាភិបាល ព្រមទាំងការលាតត្រដាងព័ត៌មានជំនួយរដ្ឋាភិបាលក្នុងទម្រង់ផ្សេងៗ។**

២ ស្តង់ដានេះមិនផ្តល់ដំណោះស្រាយចំពោះ :

(ក) បញ្ហាពិសេសណាមួយ ដែលកើតឡើងក្នុង គណនេយ្យចំពោះអំណោយរដ្ឋាភិបាលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ដោយឆ្លុះបញ្ចាំងពីឥទ្ធិពលបំរែបំរួលថ្លៃឬព័ត៌មានបន្ទាប់បន្សំក្នុងលក្ខណៈប្រហាក់ប្រហែល។

(ខ) ជំនួយរដ្ឋាភិបាល ដែលត្រូវបានផ្តល់ជូនអង្គភាពមួយក្នុងទម្រង់ជាអត្ថប្រយោជន៍ផ្សេងៗ ដែលធ្វើឡើងដើម្បីកំណត់នូវប្រាក់ចំណេញ ឬប្រាក់ខាតជាប់ពន្ធ ឬដើម្បីកំណត់ ឬកម្រិតមូលដ្ឋាននៃបំណុល

[1] ជាផ្នែកមួយនៃការកែលម្អ IFRS ដែលបានបោះផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨ ក្រុមប្រឹក្សាបានកែប្រែពាក្យបច្ចេកទេសមួយចំនួនដែលបានប្រើប្រាស់ក្នុងស្តង់ដានេះ ដើម្បីឲ្យស្របទៅតាម IFRS ផ្សេងទៀតដូចតទៅ÷ (ក) “ប្រាក់ចំណូលជាប់ពន្ធ” ត្រូវបានកែជា “ប្រាក់ចំណេញ ឬប្រាក់ខាតជាប់ពន្ធ” (ខ) “ត្រូវបានទទួលស្គាល់ជាចំណូល ឬចំណាយ” ត្រូវបានកែសម្រួលជា “ត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬខាត” (គ) “ត្រូវបានកត់ត្រាខាងឥណទានដោយផ្ទាល់ចូលទៅក្នុងភាគកម្ម/មូលនិធិផ្ទាល់របស់ម្ចាស់ហ៊ុន” ត្រូវបានកែប្រែជា “ត្រូវបានទទួលស្គាល់ក្រៅប្រាក់ចំណេញ ឬខាត” (ឃ) “ការកែប្រែឡើងវិញនៃការប៉ាន់ស្មានគណនេយ្យ” ត្រូវបានប្តូរជា ”ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ”

ពន្ធលើប្រាក់ចំណេញ។ ឧទាហរណ៍នៃអត្ថប្រយោជន៍ទាំងនោះគឺ ពន្ធលើប្រាក់ចំណេញ ថ្ងៃវិស្សមកាល ឥណទានពន្ធលើវិនិយោគ វិភាជន៍ការកាត់រំលស់ដែលកើនឡើងនិងអត្រាពន្ធលើប្រាក់ចំណេញ ថយចុះ។

(គ) ការចូលរួមរបស់រដ្ឋាភិបាលក្នុងភាពជាម្ចាស់របស់អង្គភាព។

(ឃ) អំណោយរដ្ឋាភិបាលក្រោម ស.គ.អ ៤១ *កសិកម្ម*

## និយមន័យ

៣ វាក្យស័ព្ទខាងក្រោម ត្រូវបានប្រើប្រាស់ក្នុងស្តង់ដានេះ ដោយមានអត្ថន័យជាក់លាក់ ÷

*រដ្ឋាភិបាល* សំដៅទៅលើរដ្ឋាភិបាលភ្នាក់ងាររដ្ឋាភិបាល ឬស្ថាប័នប្រហាក់ប្រហែលថ្នាក់មូលដ្ឋាន ជាតិ ឬអន្តរជាតិ

*ជំនួយរដ្ឋាភិបាល* គឺជាសកម្មភាពរបស់រដ្ឋាភិបាលដែលត្រូវបានគេរៀបចំឡើង ដើម្បីផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច ចំពោះអង្គភាព មួយ ឬច្រើនដែលមានគុណសម្បត្តិសមស្របតាមលក្ខណៈវិនិច្ឆ័យជាក់លាក់។ ចំពោះគោលបំណងនៃស្តង់ដារនេះ ជំនួយរដ្ឋាភិបាលមិនរួមបញ្ចូលអត្ថប្រយោជន៍ដែលបានផ្តល់ដោយប្រយោលតាមរយៈសកម្មភាពដែលផ្តល់ផលប៉ះពាល់ដល់ស្ថានភាពពាណិជ្ជកម្ម ទូទៅដូចជា ការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ កំពុងអភិវឌ្ឍន៍ ឬការដាក់របាំងពាណិជ្ជកម្មដល់គូប្រកួតប្រជែងនោះទេ។

*អំណោយរដ្ឋាភិបាល* គឺជាជំនួយទាំងឡាយរបស់រដ្ឋាភិបាលក្នុងទម្រង់ជាការផ្ទេរធនធានឲ្យអង្គភាព ដើម្បីទទួលបានត្រឡប់មកវិញនូវការអនុលោមអតីតកាល ឬអនាគតតាមលក្ខខណ្ឌជាក់លាក់ពាក់ព័ន្ធនឹងសកម្មភាពប្រតិបត្តិការរបស់អង្គភាព។ អំណោយទាំងនេះមិនរួមបញ្ចូល ជំនួយរដ្ឋាភិបាលដែលមិនអាចគិតតម្លៃសមស្រប បានព្រមទាំងប្រតិបត្តិការជាមួយរដ្ឋាភិបាលណា ដែលមិនមានភាពខុសប្លែកគ្នាពីប្រតិបត្តិការពាណិជ្ជកម្មធម្មតារបស់អង្គភាព[2]។

*អំណោយទាក់ទងនឹងទ្រព្យសកម្ម* គឺជាបណ្តាអំណោយរដ្ឋាភិបាលដែលលក្ខខណ្ឌចំបងរបស់វាគឺឲ្យអង្គភាពដែលមានលក្ខណសម្បត្តិសមស្របទិញ សាងសង់ ឬទទួលយកទ្រព្យសកម្មរយៈពេលវែង។ លក្ខខណ្ឌបន្ទាប់បន្សំអាចជាការកំណត់ចងភ្ជាប់អំពីប្រភេទ ឬទីតាំងទ្រព្យសកម្ម ឬរយៈពេលដែលទ្រព្យសកម្មទាំងនោះត្រូវបានទិញ ឬរក្សាទុក។

*អំណោយទាក់ទងនឹងចំណូល* គឺរាល់អំណោយរដ្ឋាភិបាលទាំងឡាយណាដែលមិនមែនជាអំណោយទាក់ទងទៅនឹងទ្រព្យសកម្ម។

*បំណុលដែលអាចលើកលែង* គឺជាបំណុលដែលម្ចាស់ បំណុលលើកលែងការសង ទៅតាមលក្ខខណ្ឌជាក់លាក់ដែលបានចែង ។

*តម្លៃទីផ្សារ* គឺជាតម្លៃដែលទ្រព្យសកម្មមួយអាចត្រូវបានដោះដូររវាងអ្នកលក់ និងអ្នកទិញដែលស្ម័គ្រចិត្ត និងមានការយល់ដឹង និងមិនស្គាល់គ្នា។

---

[2] សូមមើល SIC-10 *ជំនួយរដ្ឋាភិបាល - ពុំមានទំនាក់ទំនងជាក់លាក់ជាមួយនឹងសកម្មភាពប្រតិបត្តិការ*

៤ ជំនួយរដ្ឋាភិបាល អាចមានច្រើនទម្រង់ ប្រែប្រួលទៅតាមលក្ខណៈជំនួយដែលបានផ្តល់ និងលក្ខខណ្ឌចងភ្ជាប់។ គោលបំណងរបស់ជំនួយអាចជាការជំរុញឲ្យអង្គភាពចាប់ផ្តើមរកនូវដំណោះស្រាយថ្មីៗដែលជាធម្មតាអង្គភាពមិនអនុវត្តប្រសិនបើពុំមានការផ្តល់ជំនួយ។

៥ មូលហេតុចំនួនពីរបញ្ជាក់ថា ការទទួលបានរបស់អង្គភាពនូវជំនួយរដ្ឋាភិ-បាលមានសារៈសំខាន់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ទីមួយប្រសិនបើធនធានត្រូវបានផ្ទេរ ត្រូវតែមានការរកឲ្យឃើញនូវវិធីសាស្ត្រគណនេយ្យសមស្របសម្រាប់ការផ្ទេរនោះ។ ទីពីរ មានការចង់បានឲ្យមានការចង្អុលបង្ហាញ ពីវិសាលភាពនៃអត្ថប្រយោជន៍ដែលអង្គភាពបានទទួលពីជំនួយនេះក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍។ ការចង្អុលបង្ហាញនេះជួយឲ្យមានការប្រៀបធៀបគ្នារវាងរបាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាពជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុការិយបរិច្ឆេទឆ្នាំមុនៗ និងរបាយការណ៍របស់អង្គភាពដទៃទៀត។

៦ អំណោយរដ្ឋាភិបាល ជួនកាលត្រូវបានគេហៅឈ្មោះផ្សេងទៀតថាជាឧបត្ថម្ភធន ប្រាក់ជំនួយ ឬបុព្វលាភ។

## អំណោយរដ្ឋាភិបាល

**៧ អំណោយរដ្ឋាភិបាល រួមបញ្ចូលទាំងអំណោយមិនមែនរូបិយវត្ថុក្នុងតម្លៃទីផ្សារ មិនត្រូវបានគេទទួលស្គាល់ទេ លុះត្រាតែមានការធានាត្រឹមត្រូវថា÷**

**(ក) អង្គភាពនឹងគោរពតាមលក្ខខណ្ឌដែលចងភ្ជាប់ជាមួយនឹងអំណោយនោះហើយ**

**(ខ) ប្រាក់អំណោយនឹងត្រូវបានទទួល**

៨ អំណោយរដ្ឋាភិបាលនឹងមិនត្រូវបានគេទទួលស្គាល់ទេ លុះត្រាតែមានការធានាត្រឹមត្រូវថា អង្គភាពនឹងគោរពតាមលក្ខខណ្ឌដែលចងភ្ជាប់ជាមួយនឹងអំណោយហើយប្រាក់អំណោយនឹងត្រូវបានទទួល។ការទទួលបានអំណោយរដ្ឋាភិបាលមិនបានផ្តល់នូវភស្តុតាងឲ្យប្រាកដថា លក្ខខណ្ឌនានាដែលបានចងភ្ជាប់ជាមួយនឹងអំណោយត្រូវបាន ឬនឹងត្រូវបានគេបំពេញនោះទេ។

៩ លក្ខណៈដែលអំណោយមួយត្រូវបានទទួលមិនជះឥទ្ធិពល ដល់វិធីសាស្រ្តគណនេយ្យដែលជ្រើសរើសយកមកប្រើពាក់ព័ន្ធនឹងអំណោយទេ។ ដូច្នេះ អំណោយ ត្រូវបានគិតក្នុងលក្ខណៈដូចគ្នា ទោះបីជាវាត្រូវបានទទួលជាសាច់ប្រាក់ ឬក៏ជាការកាត់បន្ថយបំណុលដែលជំពាក់រដ្ឋាភិបាលក៏ដោយ។

១០ បំណុលដែលអាចលើកលែង ពីរដ្ឋាភិបាល ត្រូវបានចាត់ទុកជាអំណោយរដ្ឋាភិបាលនៅពេលដែលមានការធានាត្រឹមត្រូវថា អង្គភាពនឹងបំពេញនូវរាល់លក្ខន្តិកៈសម្រាប់ការលើកលែងបំណុល។

១០ក អត្ថប្រយោជន៍ នៃបំណុលរដ្ឋាភិបាល ដែលគិតអត្រាការប្រាក់ទាបជាងទីផ្សារ គឺត្រូវបានគេចាត់បញ្ចូលជាអំណោយរដ្ឋាភិបាល។ បំណុលគួរត្រូវបានគេទទួលស្គាល់ និងវាស់វែងស្របទៅតាម ស.រ.ហ.អ ៩ *ឧបករណ៍ហិរញ្ញវត្ថុ*។ អត្ថប្រយោជន៍របស់ការប្រាក់ទាបជាងទីផ្សារ គួរតែត្រូវបានវាស់វែងថា ជាភាពខុសគ្នារវាងតម្លៃនៅសល់ដំបូងនៃ បំណុល ដែលបានកំណត់តាមស.រ.ហ.អ៩និងចំណូលពីការលក់ដែលបានទទួល។អត្ថប្រយោជន៍នេះត្រូវកត់ត្រាស្របទៅតាមស្តង់ដាមួយនេះ។ អង្គភាពគួរពិចារណាអំពីលក្ខខណ្ឌ និងកាតព្វកិច្ច ដែលបានបំពេញ ឬត្រូវបំពេញ នៅពេលកំណត់ថ្លៃដើមដែលទូទាត់សងដោយអត្ថប្រយោជន៍បំណុល ។

១១ ពេលដែលអំណោយរដ្ឋាភិបាល ត្រូវបានគេទទួលស្គាល់ នោះរាល់ទ្រព្យសកម្ម ឬបំណុលយថាហេតុដែលពាក់ព័ន្ធ ត្រូវបានគេកត់ត្រាស្របតាម ស.គ.អ ៣៧ *សំវិធានធន បំណុលជាយថាហេតុ និងទ្រព្យសកម្មជាយថាហេតុ*។

**១២ អំណោយរដ្ឋាភិបាលត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតតាមមូលដ្ឋានជាប្រព័ន្ធក្នុងការិយបរិច្ឆេទដែលអង្គភាពទទួលស្គាល់ជាចំណាយនូវរាល់ថ្លៃដើមពាក់ព័ន្ធ ដែលត្រូវទូទាត់សងដោយអំណោយ។**

១៣ មានវិធីសាស្រ្តចម្បងពីរ ទាក់ទងនឹងគណនេយ្យ សម្រាប់អំណោយរដ្ឋាភិបាល៖ វិធីសាស្រ្តមូលធន ជាវិធីសាស្រ្តមួយដែលអំណោយ ត្រូវបានគេទទួលស្គាល់មិននៅក្នុងរបាយការណ៍ចំណេញ ឬខាត រីឯវិធីសាស្រ្តចំណូល ជាវិធីមួយដែលអំណោយ ត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទមួយ ឬច្រើន។

១៤ អ្នកដែលគាំទ្រវិធីសាស្រ្តមូលធនផ្តល់មតិដូចខាងក្រោម៖

(ក) អំណោយរដ្ឋាភិបាល ជាធាតុហិរញ្ញប្បទាន ហើយវាគួរតែដាក់បញ្ចូលទៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ជាជាងទទួលស្គាល់ក្នុង របាយការណ៍ចំណេញ ឬខាត ដើម្បីកាត់កងរាល់ចំណាយដែលគេផ្តល់ហិរញ្ញវត្ថុ។ អំណោយនោះ គួរតែមិនត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ ចំណេញ ឬខាត ព្រោះការសងពុំត្រូវបានគេរំពឹងទុក ។

(ខ) ការទទួលស្គាល់អំណោយរដ្ឋាភិបាលក្នុងរបាយការណ៍ចំណេញ ឬខាតជាការមិនត្រឹមត្រូវ ដោយមូលហេតុថា អំណោយទាំងនោះពុំ

មែនជាប្រាក់ចំណូលដែលរកបាន ប៉ុន្តែវាគ្រាន់តែជាគ្រឿងលើកទឹកចិត្តដែលរដ្ឋាភិបាលផ្តល់ឲ្យដោយគ្មានចំណាយថ្លៃដើម ។

១៥ មតិគាំទ្រវិធីសាស្រ្តចំណូលមានដូចខាងក្រោម÷

(ក) ដោយសារតែអំណោយរដ្ឋាភិបាល គឺជាការទទួលបានពីប្រភពមួយដែលពុំមែនជា ម្ចាស់ហ៊ុន ដូច្នេះវាមិនគួរត្រូវបានគេទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធនផ្ទាល់ទេ ប៉ុន្តែវាគួរតែត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត នៃការិយបរិច្ឆេទសមស្រប។

(ខ) អំណោយរដ្ឋាភិបាលកម្រមិនសមហេតុផល។ អង្គភាពទទួលបានអំណោយនេះតាមរយៈការអនុលោមតាមលក្ខខណ្ឌ និងបំពេញបាននូវកាតព្វកិច្ចដែលរំពឹងទុក។ អំណោយទាំងនោះគួរតែត្រូវបានគេទទួលស្គាល់ក្នុង របាយការណ៍ចំណេញ ឬខាត ក្នុងកំឡុងការិយបរិច្ឆេទដែលអង្គភាពទទួលស្គាល់ចំណាយថ្លៃដើមពាក់ព័ន្ធដែលត្រូវទូទាត់ជាមួយនឹងអំណោយ។

(គ) ដោយសារតែចំណូល និងពន្ធផ្សេងៗជាចំណាយ ដូច្នេះវាការសមហេតុផល ដែលអំណោយរដ្ឋាភិបាល ដែលជាការពង្រីកគោលនយោបាយសារពើពន្ធ ត្រូវកត់ចូលក្នុងរបាយការណ៍ចំណេញ-ខាត។

១៦ ចំពោះវិធីសាស្រ្តចំណូល វាមានសារៈសំខាន់ដែលអំណោយរដ្ឋាភិបាលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត តាមមូលដ្ឋានជាប្រព័ន្ធក្នុងការិយបរិច្ឆេទ ដែលអង្គភាពទទួលស្គាល់ចំណាយថ្លៃដើមពាក់ព័ន្ធ ដែលត្រូវយកអំណោយគិតទូទាត់សង។ ការទទួលស្គាល់អំណោយ

រដ្ឋាភិបាលក្នុង របាយការណ៍ចំណេញ ឬខាតតាមមូលដ្ឋាននៃការទទួលបានគឺមិនស្របទៅតាមការសន្មត់គណនេយ្យបង្គរឡើយ (មើល ស.គ.អ ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ*) តែវិធីសាស្ត្រនេះអាចត្រូវបានទទួលស្គាល់ ក្នុងករណីដែលពុំមានមូលដ្ឋាន ដើម្បីបែងចែកអំណោយទៅតាមការិយបរិច្ឆេទ។

១៧ ក្នុងករណីភាគច្រើន ការិយបរិច្ឆេទដែលអង្គភាពទទួលស្គាល់ថ្លៃដើម និងចំណាយពាក់ព័ន្ធនឹងអំណោយរដ្ឋាភិបាលគឺអាចបញ្ជាក់ឲ្យដឹងបាន។ ដូច្នេះការទទួលស្គាល់ចំណាយជាក់លាក់ទាក់ទងនឹងអំណោយ ត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទ ដូចគ្នានឹងចំណាយពាក់ព័ន្ធ។ ដូចគ្នានេះដែរ អំណោយទាក់ទងនឹងទ្រព្យសកម្ម ដែលអាចដករំលស់ ជាធម្មតាត្រូវបានគេទទួលស្គាល់ ទៅតាមការិយបរិច្ឆេទ ហើយសមមាត្រនៃការចំណាយរំលស់លើទ្រព្យសម្បត្តិនោះត្រូវតែទទួលស្គាល់។

១៨ អំណោយពាក់ព័ន្ធនឹងទ្រព្យសកម្មដែលមិនអាចដករំលស់ ត្រូវការបំពេញកាតព្វកិច្ចជាក់លាក់មួយចំនួន ហើយបន្ទាប់មកទើបគេទទួលស្គាល់វាក្នុងរបាយការណ៍ចំណេញ ឬខាតតាមការិយបរិច្ឆេទដែលកើតមាននូវចំណាយថ្លៃដើមក្នុងការបំពេញកាតព្វកិច្ចទាំងនោះ។ ជាឧទាហរណ៍ អំណោយដីអាចភ្ជាប់នឹងលក្ខខណ្ឌសាងសង់អគារលើដីនោះ ហើយវាជាការសមស្របដែលត្រូវទទួលស្គាល់អំណោយក្នុងរបាយការណ៍ចំណេញ ឬខាត ទៅតាមអាយុកាលរបស់អគារ ។

១៩ អំណោយមានពេលខ្លះ ត្រូវបានទទួលជាផ្នែកនៃកញ្ចប់ជំនួយសារពើពន្ធ ឬហិរញ្ញវត្ថុ ដែលមានលក្ខខណ្ឌចងភ្ជាប់មួយចំនួន។ ក្នុងករណីដូចនេះត្រូវមានការប្រុងប្រយ័ត្នក្នុងការកំណត់នូវលក្ខខណ្ឌ ដែលអាចនាំឲ្យកើត

មាននូវថ្លៃដើម និងចំណាយផ្សេងៗ ដែលជាកត្តាកំណត់ការិយបរិច្ឆេទដែលអំណោយត្រូវបានទទួល។ គេអាចបែងចែកផ្នែកខ្លះនៃអំណោយតាមមូលដ្ឋានមួយ រីឯផ្នែកខ្លះទៀតតាមមូលដ្ឋានមួយផ្សេងទៀត។

២០ **អំណោយរដ្ឋាភិបាលដែលក្លាយជាប្រាក់ត្រូវទទួលក្នុងការទូទាត់សងរាល់ចំណាយ ឬការខាតបង់ដែលបានកើតមាន ឬសម្រាប់គោលបំណងផ្តល់ជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុជាបន្ទាន់ដល់អង្គភាព ដោយពុំមានចំណាយថ្លៃដើមពាក់ព័ន្ធនាពេលអនាគត ត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលជំនួយនោះក្លាយជាប្រាក់ត្រូវទទួល។**

២១ ក្នុងកាលៈទេសៈខ្លះ អំណោយរដ្ឋាភិបាលអាចត្រូវបានផ្តល់ក្នុងគោលបំណងផ្តល់នូវជំនួយគាំទ្រហិរញ្ញវត្ថុជាបន្ទាន់ ដល់អង្គភាពមួយ ជំនួសការលើកទឹកចិត្តអនុវត្តចំណាយជាក់លាក់។ អំណោយបែបនោះអាចកំណត់ផ្តល់ឱ្យអង្គភាពជាក់លាក់ណាមួយ ហើយវាមិនអាចផ្តល់ឱ្យទៅអ្នកទទួលផលគ្រប់ប្រភេទនោះទេ។ ករណីនេះអនុញ្ញាតឱ្យទទួលស្គាល់អំណោយក្នុងរបាយ-ការណ៍ចំណេញឬខាត ក្នុងការិយបរិច្ឆេទដែលអង្គភាពនោះមានសិទ្ធិទទួលបានអំណោយនោះ ដោយមានការលាតត្រដាងព័ត៌មាន ដើម្បីធានាការយល់ដឹងឱ្យច្បាស់ពីឥទ្ធិពលរបស់វា។

២២ អំណោយរដ្ឋាភិបាលអាចក្លាយជាប្រាក់ត្រូវទទួលរបស់អង្គភាព ដើម្បីទូទាត់សងចំណាយ ឬការខាតបង់ ដែលកើតមានក្នុង ការិយបរិច្ឆេទគ្រាមុន។ អំណោយនោះ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទ ដែលអំណោយនោះក្លាយជាប្រាក់ត្រូវទទួល ដោយមានការលាតត្រដាងព័ត៌មានដើម្បីធានាការយល់ដឹងឱ្យច្បាស់ពីឥទ្ធិពលរបស់វា។

## អំណោយរដ្ឋាភិបាលមិនមែនរូបិយវត្ថុ

២៣ អំណោយរដ្ឋាភិបាលអាចមានទម្រង់ជា ការផ្ទេរទ្រព្យសកម្មមិនមែនរូបិយវត្ថុ ដូចជា ដី ឬធនធានផ្សេងៗដើម្បីឲ្យអង្គភាពប្រើប្រាស់។ ក្នុងករណីនេះ ជាធម្មតាគេវាយតម្លៃទ្រព្យសកម្មមិនមែនរូបិយវត្ថុតាមតម្លៃទីផ្សារ ហើយកត់ត្រា អំណោយ និងទ្រព្យសកម្មទាំងពីរតាមតម្លៃទីផ្សារ។ ជំរើសមួយផ្សេងទៀតគឺពេលខ្លះទាំងទ្រព្យសកម្ម និងអំណោយត្រូវបានគេកត់ត្រាតាមតម្លៃធម្មតា។

## ការបង្ហាញព័ត៌មានអំពីអំណោយដែលពាក់ព័ន្ធនឹងទ្រព្យសកម្ម

២៤ **អំណោយរដ្ឋាភិបាលពាក់ព័ន្ធនឹងទ្រព្យសកម្ម ក្នុងនោះរួមទាំងអំណោយមិនមែនរូបិយវត្ថុតាមតម្លៃទីផ្សារ ត្រូវបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ តាមរយៈការដាក់អំណោយថាជាចំណូលពន្យា ឬដោយដកអំណោយចេញដើម្បីទទួលបានតម្លៃនៅសល់របស់ទ្រព្យសកម្ម។**

២៥ មានវិធីសាស្ត្រ ពីរ ដែលជាជម្រើស អាចទទួលយកបានក្នុងការបង្ហាញព័ត៌មានអំណោយ (ឬចំណែកសមស្របខ្លះនៃអំណោយ) ពាក់ព័ន្ធនឹងទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

២៦ វិធីសាស្ត្រទី១ ទទួលស្គាល់អំណោយ ថាជាចំណូលពន្យា ដែលត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត តាមមូលដ្ឋានជាប្រព័ន្ធផ្អែកតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម។

២៧ វិធីសាស្ត្រមួយផ្សេងទៀត ដកអំណោយចេញដើម្បីទទួលបានតម្លៃនៅសល់របស់ទ្រព្យសកម្ម។ អំណោយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ

ឬខាត ថាជាចំណាយកាត់រំលស់ថយ ទៅលើអាយុកាល របស់ទ្រព្យសកម្ម ដែលអាចដករំលស់។

២៨ ការទិញទ្រព្យសកម្ម និងការទទួលបាននូវអំណោយដែលពាក់ព័ន្ធ អាចជាមូលហេតុបណ្តាលឲ្យមាន ចលនាសំខាន់ក្នុង លំហូរសាច់ប្រាក់ របស់អង្គភាព។ ដោយហេតុផលនេះ ដើម្បីបង្ហាញពីការវិនិយោគទ្រព្យសកម្មដុល ចលនាទាំងនោះជាញឹកញាប់ ត្រូវបានលាតត្រដាងជាធាតុដាច់ដោយឡែកក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ដោយមិនគិតទេថាអំណោយត្រូវបានដក ឬមិនបានដកចេញពីទ្រព្យសកម្មដែលពាក់ព័ន្ធ សម្រាប់គោលបំណងបង្ហាញព័ត៌មានក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ការបង្ហាញព័ត៌មានអំពីអំណោយពាក់ព័ន្ធនឹងចំណូល

២៩ អំណោយដែលពាក់ព័ន្ធនឹងចំណូល មានពេលខ្លះត្រូវបានគេបង្ហាញថាជាឥណទានក្នុង របាយការណ៍ប្រាក់ចំណេញសរុប ក្រោមចំណងជើងដាច់ដោយឡែក ឬ ទូទៅដូចជា “ចំណូលផ្សេងៗ” ឬ ជំរើសផ្សេងទៀតគឺអំណោយត្រូវបានដកក្នុងសេចក្តីរាយការណ៍ចំណាយពាក់ព័ន្ធ។

២៩ក ប្រសិនបើ អង្គភាពមួយ បង្ហាញសមាសធាតុប្រាក់ចំណេញ ឬខាត ក្នុងរបាយការណ៍ចំណូលដូចដែលមានពណ៌នាក្នុងកថាខណ្ឌ ៨១នៃ ស.គ.អ ១ (ដូចដែលបានកែសម្រួលក្នុងឆ្នាំ២០០៧) អង្គភាពនោះត្រូវបង្ហាញអំណោយដែលពាក់ព័ន្ធនឹងចំណូលដូចដែលបានទាមទារក្នុង កថាខណ្ឌ ២៩ ក្នុងរបាយការណ៍ដាច់ដោយឡែក។

៣០ អ្នកគាំទ្រវិធីសាស្ត្រទីមួយអះអាងថា វាជាការមិនសមស្របក្នុងការសរុបធាតុចំណូល និងចំណាយ ហើយការបំបែកអំណោយចេញពីចំណាយ ជួយដល់

ការប្រៀបធៀបជាមួយនឹង ចំណាយដទៃទៀត ដែលមិនប៉ះពាល់ដោយអំណោយ។ ចំពោះវិធីសាស្ត្រទីពីរ មានការផ្តល់មតិថា ចំណាយអាចមិនកើតមានក្នុងអង្គភាព ប្រសិនបើពុំមានអំណោយ នោះការបង្ហាញព័ត៌មានដោយពុំមានកាត់កងអំណោយអាចជាការបង្ហាញខុស ។

៣១ វិធីសាស្ត្រទាំង ពីរ សុទ្ធតែអាចទទួលយកបាន ក្នុងការបង្ហាញព័ត៌មានអំណោយដែលពាក់ព័ន្ធនឹងចំណូល។ ការលាតត្រដាងអំណោយអាចជាចាំបាច់ សម្រាប់ការយល់ដឹងឲ្យបានត្រឹមត្រូវពី របាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងពីឥទ្ធិពលរបស់អំណោយលើធាតុចំណូល ឬចំណាយ ដែលត្រូវការលាតត្រដាងដាច់ពីគ្នា គឺជាការសមស្រប។

## ការសងអំណោយរដ្ឋាភិបាល

**៣២ អំណោយរដ្ឋាភិបាលដែលត្រូវសងអាចកត់ត្រាជាការផ្លាស់ប្តូរលើការប៉ាន់ស្មានគណនេយ្យ (មើល ស.គ.អ ៨ *គោលនយោបាយគណនេយ្យការផ្លាស់ប្តូរលើការប៉ាន់ស្មានគណនេយ្យ និងលំអៀងនានា*)។ ការសងអំណោយដែលពាក់ព័ន្ធនឹងចំណូលត្រូវអនុវត្តជាដំបូងទល់នឹងឥណទានពន្យាដែលមិនដករំលស់ទាក់ទងនឹងជំនួយ។ ករណីដែលការសងលើសពីឥណទានពន្យា ឬនៅពេលដែលពុំមានឥណទានពន្យា ការសងត្រូវទទួលស្គាល់ភ្លាមៗនៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ការសងអំណោយពាក់ព័ន្ធនឹងទ្រព្យសកម្មត្រូវបានគេទទួលស្គាល់ដោយបង្កើនតម្លៃនៅសល់របស់ទ្រព្យសកម្ម ឬកាត់បន្ថយសមតុល្យចំណូលពន្យានូវចំនួនដែលត្រូវសង។ រំលស់បន្ថែមបង្គរដែលត្រូវទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬខាតក្នុងគ្រា**

**ដោយពុំមានអំណោយ ត្រូវទទួលស្គាល់ភ្លាមៗក្នុងរបាយការណ៍ចំណេញ ឬខាត។**

៣៣ ករណីដែលឈានដល់ការសងអំណោយ ដែលពាក់ព័ន្ធនឹង ទ្រព្យសកម្ម អាចត្រូវការតម្លៃតបស្នង ដើម្បីផ្តល់ដល់ការថយចុះតម្លៃ ដែលអាចកើតមានចំពោះតម្លៃនៅសល់ថ្មីនៃទ្រព្យសកម្ម។

## ជំនួយរដ្ឋាភិបាល

៣៤ ដោយមិនរួមបញ្ចូលក្នុងនិយមន័យ នៃអំណោយរដ្ឋាភិបាលក្នុងកថាខណ្ឌទី៣ គឺជាទម្រង់ជាក់លាក់នៃជំនួយរដ្ឋាភិបាលដែលពុំមានតម្លៃសមស្រប ហើយប្រតិបត្តិការជាមួយនឹងរដ្ឋាភិបាលដែលមិនអាចញែកដាច់ចេញពីប្រតិបត្តិការអាជីវកម្មធម្មតារបស់អង្គភាព។

៣៥ ឧទាហរណ៍នៃជំនួយ ដែលពុំមានតម្លៃសមស្រប មានដំបូន្មានទីផ្សារ ឬបច្ចេកទេសដោយឥតគិតថ្លៃ និងការផ្តល់នូវការធានា។ ឧទាហរណ៍នៃជំនួយ ដែលមិនអាចញែកដាច់ពីប្រតិបត្តិការពាណិជ្ជកម្មធម្មតារបស់អង្គភាពគឺ គោលនយោបាយលទ្ធកម្មរបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវចំពោះចំណែកមួយនៃការលក់របស់អង្គភាព។ អត្ថិភាពនៃអត្ថប្រយោជន៍អាចជាការជាក់ស្តែង ប៉ុន្តែរាល់បំណងបំបែកសកម្មភាពពាណិជ្ជកម្ម ចេញពីជំនួយរដ្ឋាភិបាលអាចនឹងមិនមានភាពត្រឹមត្រូវ ។

៣៦ សារៈសំខាន់ នៃអត្ថប្រយោជន៍ក្នុងឧទាហរណ៍ខាងលើដូចជា ការលាតត្រដាងពីលក្ខណៈ វិសាលភាព និងថេរវេលារបស់ជំនួយ គឺជាការចាំបាច់ដើម្បីកុំឲ្យរបាយការណ៍ហិរញ្ញវត្ថុខុសឆ្គង។

៣៧ លុបចេញ

៣៨ ក្នុងស្តង់ដានេះ ជំនួយរដ្ឋាភិបាលមិនរួមបញ្ចូលការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ដោយការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទំនាក់ទំនង និងដឹកជញ្ជូនទូទៅ និងការផ្តល់នូវប្រព័ន្ធដែលបានកែលម្អដូចជា ប្រព័ន្ធបង្ហូរទឹក ឬធារាសាស្ត្រ ដែលអាចកើតមាន តាមមូលដ្ឋានមិនច្បាស់លាស់ជាបន្តបន្ទាប់ ដើម្បីជាប្រយោជន៍ដល់សហគមន៍ក្នុងតំបន់ទាំងមូល។

## ការលាតត្រដាងព័ត៌មាន

៣៩ បញ្ហាខាងក្រោមត្រូវធ្វើការលាតត្រដាង÷

(ក) គោលនយោបាយគណនេយ្យដែលត្រូវជ្រើសយកមក ប្រើប្រាស់សំរាប់អំណោយរដ្ឋាភិបាលរួមមាន វិធីសាស្ត្រនៃការបង្ហាញ ដែលបានប្រើប្រាស់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(ខ) លក្ខណៈ វិសាលភាពនៃអំណោយរដ្ឋាភិបាលដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការចង្អុលបង្ហាញទម្រង់ផ្សេងទៀតនៃជំនួយរដ្ឋាភិបាលដែលអង្គភាពបានទទួលផលដោយផ្ទាល់ព្រមទាំង

(ខ) លក្ខខណ្ឌទាំងឡាយដែលមិនទាន់បានបំពេញ និងយថាហេតុនានាដែលភ្ជាប់ជាមួយ នឹងជំនួយរដ្ឋាភិបាលដែលត្រូវបានទទួលស្គាល់ ។

## បទប្បញ្ញត្តិអន្តរកាល

៤០ អង្គភាពដែលជ្រើសប្រើប្រាស់ស្តង់ដានេះជាលើកដំបូងត្រូវ÷

(ក) អនុលោមទៅតាមការតម្រូវនៃការលាតត្រដាងព័ត៌មាននៅកន្លែងដែលសមស្របនិង

(ខ) អាចជា ÷

(i) កែតម្រូវរបាយការណ៍ហិរញ្ញវត្ថុសំរាប់បំលាស់ប្តូរគោលនយោបាយគណនេយ្យស្របតាម ស.គ.អ ៨ ឬ

(ii) អនុវត្តបទប្បញ្ញត្តិគណនេយ្យរបស់ស្តង់ដាតែទៅលើអំណោយ ឬចំណែកខ្លះនៃអំណោយដែលបានក្លាយជាប្រាក់ត្រូវទទួល ឬត្រូវសងក្រោយកាលបរិច្ឆេទចូលជាធរមានរបស់ស្តង់ដានេះ។

## កាលបរិច្ឆេទចូលជាធរមាន

៤១ ស្តង់ដានេះអាចអនុវត្តបានចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលការិយបរិច្ឆេទចាប់ផ្តើមនៅត្រឹម ឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨៤

៤២ ស.គ.អ ១ (ដូចដែលបានកែសម្រួលក្នុងឆ្នាំ២០០៧) បានកែប្រែពាក្យបច្ចេកទេសដែលបានប្រើប្រាស់ក្នុង ស.រ.ហ.អ ។ បន្ថែមលើនេះ វាបានបន្ថែមកថាខណ្ឌ២៩ក។ អង្គភាពមួយអាចយកការកែប្រែទាំងនោះទៅប្រើប្រាស់សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពមួយប្រើប្រាស់ ស.គ.អ ១ (បានកែតម្រូវក្នុងឆ្នាំ២០០៧) សម្រាប់ការិយបរិច្ឆេទមុនៗ ការកែប្រែគួរតែត្រូវអនុវត្តសម្រាប់ការិយបរិច្ឆេទមុន។

៤៣ កថាខណ្ឌ ៣៧ ត្រូវបានលុបចេញ ហើយកថាខណ្ឌ ១០ក ត្រូវបានបន្ថែមចូលដោយ *បសិដ្ឋកម្មចំពោះ ស.រ.ហ.អ* ដែលបានចេញផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវអនុវត្តការកែប្រែទាំងនោះតាមលំដាប់លំដោយចំពោះបំណុលរដ្ឋាភិបាលដែលបានទទួលក្នុងការិយ

បរិច្ឆេទ ដែលចាប់ផ្ដើមនៅ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩ ។ យកទៅអនុវត្តមុនពេលកំណត់អាចអនុញ្ញាតបាន ប្រសិនបើអង្គភាព មួយ ប្រើប្រាស់ការកែប្រែទាំងនោះសម្រាប់ការិយបរិច្ឆេទមុនៗ អង្គភាពនោះត្រូវ លាតត្រដាងការពិត។

៤៤ ស.រ.ហ.អ ៩ ដែលត្រូវបានចេញផ្សាយក្នុងខែតុលា ឆ្នាំ២០១០ បានកែប្រែកថាខណ្ឌ ១០ក។ អង្គភាពមួយត្រូវយកការកែប្រែនោះទៅប្រើប្រាស់ នៅពេលដែលអង្គភាពអនុវត្ត ស.រ.ហ.អ ៩ ដូចដែលបានចេញផ្សាយ ក្នុងខែតុលា ឆ្នាំ២០១០ ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ